# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ០៩.កយ.ប្រក-២០០៦

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/០៧ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- អនុលោមតាមមាត្រា៧១ ថ្មី មាត្រា ៧២ និងមាត្រា ៧៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**សម្រេច**

**ប្រការ ១**

ប្រគល់តួនាទីជាអាជ្ញាធរដែលត្រូវសម្រេចអំពីការប្រើប្រាស់នីតិវិធី នៃការប្រគល់ដោយមានការឃ្លាំមើល ឬការញុះញង់ឱ្យលក់ ជូនមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**ប្រការ ២**

សេចក្តីសម្រេចអំពីការប្រើនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬការញុះញង់ឱ្យលក់ដែលធ្វើតាមករណីនីមួយៗ ត្រូវឱ្យស្របទៅនឹងមាត្រា ៧១ ថ្មី មាត្រា ៧២ និងមាត្រា ៧៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងប្រកាសនេះ ។

ក្នុងករណីបន្ទាន់ដែលចាំបាច់ត្រូវប្រើប្រាស់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើលឬការញុះញង់ឱ្យលក់ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចលើទីតាំងដែលត្រូវអនុវត្តនីតិវិធីនោះ អាចសម្រេចឱ្យមានការប្រើប្រាស់នីតិវិធីនេះ បានក្នុងនាមមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាដែលចេញសេចក្តីសម្រេចត្រូវជូនដំណឹងភ្លាម ទៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**ប្រការ ៣ អំពីការប្រគល់ដោយមានការឃ្លាំមើល**

ក្នុងការអនុវត្តន៍នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើលទៅលើបទល្មើសណាមួយ អាជ្ញាធរអាចសម្រេចឱ្យប្រើប្រាស់៖

-គ្រឿងញៀន ដែលមានចែងនៅក្នុងមាត្រា ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

-ឧបករណ៍ បរិក្ខារ ឬសម្ភារដទៃៗទៀតដែលជនល្មើសប៉ុនប៉ងយកទៅប្រើប្រាស់ ឬកំពុងប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមូលនិធិ ឬវត្ថុមានតម្លៃដទៃៗទៀតដែលពាក់ព័ន្ធទៅនឹងបទល្មើសណាមួយនោះ ។

-ការប្រើប្រាស់វិធីខាងលើនេះ គឺក្នុងគោលបំណងដើម្បីសម្រួលដល់ការស៊ើបអង្កេតឱ្យមានប្រសិទ្ធភាព ដោយអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយដូចជាការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិតជាមួយជនល្មើសក្នុងអំពើណាមួយ ដើម្បីកំណត់ឱ្យបានច្បាស់អំពីបទល្មើសនោះនិងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់ ។

ប្រសិនបើរដ្ឋបរទេសមានការពាក់ព័ន្ធនៅក្នុងសកម្មភាពនេះសេចក្តីសម្រេចឱ្យប្រើប្រាស់ ការប្រគល់ដោយមានការឃ្លាំមើល ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងជាមួយរដ្ឋដែលពាក់ព័ន្ធទាំងនោះ ។

ការជូនដំណឹងអំពីសេចក្តីសម្រេចឱ្យប្រើប្រាស់ ការប្រគល់ដោយមានការឃ្លាំមើលទៅព្រះរាជអាជ្ញានៃទីកន្លែងដែលត្រូវអនុវត្តសេចក្តីសម្រេចនេះត្រូវធ្វើឡើងឱ្យស្របតាមមាត្រា២នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ក្រៅពីមានសិទ្ធិសម្រេចឱ្យប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវដឹកនាំត្រួតពិនិត្យ និងដាក់បទបញ្ជាឱ្យធ្វើសកម្មភាពណាមួយដែលយល់ឃើញថាសមស្រប និងម្យ៉ាងវិញទៀតក៏មានសិទ្ធិផងដែរក្នុងការពិគ្រោះយោបល់ជាមួយអាជ្ញាធរបរទេស ដែលមានការពាក់ព័ន្ធក្នុងកិច្ចសហប្រតិបត្តិការនិងការអនុវត្តន៍នីតិវិធីនៃការប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើល ដែលត្រូវធ្វើឡើងក្នុងដែនរបស់ខ្លួនអាជ្ញាធរអាចសម្រេចឱ្យចាំស្កាត់ចាប់យកវត្ថុដែលបញ្ជូនមកខុសច្បាប់ ហើយដាក់ជំនួសវិញដោយវត្ថុផ្សេងមុនពេលបញ្ជូនបន្ត ។ ក្នុងករណីការអនុវត្តន៍នីតិវិធីការប្រគល់ដោយមានការឃ្លាំមើល ដែលមានលក្ខណៈជាអន្តរជាតិវិធានការអនុវត្តអាចសម្រេចបានទៅតាមកិច្ចប្រមព្រៀងជាមួយរដ្ឋបរទេស ដែលមានផលប្រយោជន៍ពាក់ព័ន្ធក្នុងករណីនីមួយៗ ។

មន្ត្រីអនុវត្តច្បាប់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល អាចបញ្ជាឱ្យធ្វើអន្តរាគមន៍នៅគ្រប់ដំណាក់កាលទាំងអស់នៃប្រតិបត្តិការរបស់ខ្លួន ប្រសិនបើត្រូវការទប់ស្កាត់ភាពអសន្តិសុខភ្លាមៗ ឬមានការផ្លាស់ប្តូរទិសដៅនៃការបញ្ជូនដែលមិនបានរំពឹងទុកជាមុនបាន ឬមានកាលៈទេសៈផ្សេងៗទៀតដែលជាឧបសគ្គដល់ការរឹបអូសវត្ថុបញ្ជូន ឬឱ្យធ្វើសកម្មភាពស្របច្បាប់ណាមួយសម្រាប់តទល់នឹងជនល្មើស ។

**ប្រការ ៤ អំពីការញុះញង់ឱ្យលក់ដោយខុសច្បាប់**

អាជ្ញាធរអាចសម្រេចប្រគល់សិទ្ធិដល់មន្ត្រីអនុវត្តច្បាប់ណាមួយ ឱ្យធ្វើការញុះញង់ជនទាំងឡាយណាដែលមានមូលហេតុធ្ងន់ធ្ងរល្មមសង្ស័យថាបានប្រព្រឹត្ត កំពុងប្រព្រឹត្ត ឬរៀបចំប្រព្រឹត្តបទល្មើសទាក់ទងទៅនឹងគ្រឿងញៀនដើម្បីឱ្យជននោះលក់ដោយខុសច្បាប់នូវ៖

-គ្រឿងញៀន ឬសារធាតុដទៃៗទៀត ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិង

-ឧបករណ៍ បរិក្ខា ឬសម្ភាដទៃៗទៀតដែលជនល្មើសមានចេតនាយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសដូចមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ការប្រើប្រាស់វិធីខាងលើនេះគឺក្នុងគោលបំណងដើម្បីសម្រួលដល់ការស៊ើបអង្កេតឱ្យមានប្រសិទ្ធភាព ដោយអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយ ដូចជាការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិតជាមួយជនល្មើសក្នុងអំពើណាមួយ ដើម្បីកំណត់ឱ្យបានច្បាស់អំពីបទល្មើសនោះ និងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់ ។

នៅពេលសម្រេចឱ្យប្រើប្រាស់វិធីនេះ អាជ្ញាធរត្រូវពិចារណាឱ្យបានហ្មត់ចត់ មួយផ្នែកទៅលើភស្តុតាងដែលបានប្រមូល និងមួយផ្នែកទៀតទៅលើលទ្ធភាពផ្សេងៗ ដែលជាការប្រថុយប្រថានទៅនឹងគ្រោះថ្នាក់របស់បុគ្គលដែលមានការពាក់ព័ន្ធក្នុងសកម្មភាពល្មើស ដែលតាមធម្មតា ប្រសិនជាយើងមិនញុះញង់ទេ គេពុំធ្វើដូច្នោះឡើយ ។

វិធីដូចបានកំណត់រាល់កថាខ័ណ្ឌខាងលើនេះ អាចអនុវត្តបានដោយបុគ្គលឯកជនធម្មតាក្រោមបញ្ជានិងក្រោមការត្រួតពិនិត្យផ្ទាល់របស់មន្ត្រីអនុវត្តច្បាប់ដែលបានចាត់តាំង ។

មន្ត្រីអនុវត្តច្បាប់ ឬបុគ្គលធម្មតាដែលបានទទួលការចាត់តាំងឱ្យអនុវត្តវិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ស្របទៅតាមកថាខ័ណ្ឌខាងលើនៃប្រការនេះ ឬប្រការ នៃប្រកាសនេះ មិនត្រូវទទួលនូវការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ឬផ្នែករដ្ឋប្បវេណី ចំពោះសកម្មភាពទាំងឡាយដែលខ្លួនបានធ្វើក្នុងវង្វង់សិទ្ធិដែលបានអនុញ្ញាតឡើយ ។

អនុលោមតាមមាត្រា ៧៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សេចក្តីសម្រេចរបស់អាជ្ញាធរដែលអនុញ្ញាតឱ្យប្រើប្រាស់វិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ ត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចលើទីកន្លែងដែលអាចសន្មតថាការលក់នោះនឹងត្រូវធ្វើឡើង ។

ប្រតិបត្តិការសេចក្តីសម្រេចរបស់អាជ្ញាធរ ដែលអនុញ្ញាតឱ្យប្រើប្រាស់វិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ត្រូវស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលសិទ្ធិធ្វើការត្រួតពិនិត្យ និងស្រាវជ្រាវដើម្បីបង្ក្រាបបទល្មើស ដូចមានចែងក្នុងមាត្រា១១០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អាចចេញបទបញ្ជានូវវិធានការសមស្របដើម្បីឱ្យការអនុវត្តន៍នេះទទួលបានជោគជ័យ ។

**ប្រការ ៥**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អ៊ុក វឌ្ឍឍនា**

ចម្លងជូន

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-គ្រប់អយ្យការ និងតុលាការខេត្ត ក្រុង
-ក្រសួងស្ថាប័នពាក់ព័ន្ធ
-ឯកសារ-កាលប្បវត្តិ